**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា**
**ប្រចាំនៅទីក្រុងណាននីង**
លេខ 00148 កពណក.ណាន

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**<u>កម្មវត្ថុ</u>: របាយការណ៍ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១២**

សេចក្តីដូចបានជំរាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសគោរពជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបនូវរបាយការណ៍ប្រចាំខែវិច្ឆិកា ឆ្នាំ២០១២ ដ៏ខ្ពង់ខ្ពស់ដូចតទៅ ។

**I. <u>ការងារទំនាក់ទំនងជាមួយភ្ញៀវ</u>**

- ចូលរួមពិពរណ៍ពាណិជ្ជកម្មអលង្ការនៅក្រុង Wuzhou ។
- ទស្សនកិច្ចសិក្សារោងចក្រផលិតថង់ប្លាស្ទិក (Plastic bag) សំរាប់វេចខ្ចប់ស៊ីម៉ង់ត៍នៅក្រុង Liuzhou ។
- ជួបប្រជុំជាមួយសភាពាណិជ្ជកម្ម នៅក្រុង Liuzhou ដែលមានបំណងដឹកនាំក្រុមហ៊ុនចិន ទៅវិនិយោគនៅកម្ពុជា ។
- ទស្សនកិច្ចសិក្សាស្រាវជ្រាវ ចំការតែផ្កាម្លិះ កសិដ្ឋានចិញ្ចឹមជ្រូក មាន់ ទា ដែលមានបំណងទៅវិនិយោគនៅកម្ពុជា ។
- ជួបពិភាក្សាជាមួយប្រព័ន្ធផ្សាយពត៌មានចិន Nanning Baoyu Media Co., Ltd. មានបំណងជួយផ្សព្វផ្សាយពត៌មានពាណិជ្ជកម្មវិនិយោគ ទេសចរណ៍និងពិពរណ៍តាមរយៈទស្សនាវដ្តីចិន ។
- ជួបពិភាក្សាជាមួយក្រុងហ៊ុន SINOTRANS JUILING Guangxi Transport & Storage Co., Ltd. មានបំណងរៀនចំសិក្ខាសាលានៅក្រុង Guilin ដោយអញ្ជើញទីប្រឹក្សាពាណិជ្ជកម្មកម្ពុជាធ្វើបទឧទ្ទេសនាម ។
- ជួបពិភាក្សានិងទស្សនកិច្ចសិក្សានៅក្រុមហ៊ុន BEIBU GULF International Exhibition (Group) Co., Ltd. មានបំណងអញ្ជើញក្រុមហ៊ុនកម្ពុជាទៅលក់ទំនិញនៅមជ្ឈមណ្ឌលពាណិជ្ជកម្មដែលទើបសាងសង់ថ្មីដោយរួចពន្ធនាំចូល ។
- ចូលរួមសិក្ខាសាលា "The 3rd China-ASEAN Women Entrepreneurs Start-up Forum" នៅក្រុង Liuzhou ដែលរៀបចំឡើងដោយមន្ទីរការបរទេស ។
- ជួបពិភាក្សាជាមួយក្រុមហ៊ុន ZHE JIANG XUHUAN HAIYUN Decoration Co, Ltd. មានបំណងស្វែងរកទិញឈើកៅស៊ូពីកម្ពុជា ។
- ជួបពិភាក្សាជាមួយ ALLIANCE OF SMEs, US-China Exchange Association មានបំណងវិនិយោគក្នុងការចិញ្ចឹមពពែខ្មៅនៅកម្ពុជា ។
- ជួបពិភាក្សាជាមួយក្រុមហ៊ុន SINOTRUCK មានបំណងស្វែងរកទីផ្សារលក់រថយន្តនិងគ្រឿងយន្តកសិកម្ម

នៅកម្ពុជា ។

- ចូលរួមបើកកម្មវិធី "Golden Camellia Tea Festival" នៅក្រុងណាននីងនិងទន្ទឹមនោះគេមានបំណងស្វែងរកទីផ្សារលក់តែនៅកម្ពុជា ។
- ជួបពិភាក្សាជាមួយក្រុងហ៊ុន Universal Create Corporation និងទស្សនកិច្ចកសិដ្ឋានចិញ្ចឹមសត្វក្របីដែលគេមានបំណងវិនិយោគចិញ្ចឹមសត្វក្របីដើម្បីយកទឹកដោះនៅកម្ពុជា ។
- ជួបពិភាក្សាជាមួយក្រុមហ៊ុន China Comservice Guangxi Co., Ltd. មានបំណងវិនិយោគលើប្រព័ន្ធទូរគមនាគមន៍នៅកម្ពុជា ។
- ជួបក្រុមហ៊ុន China National Heavy Duty Truck Group Co., Ltd. មានបំណងស្វែងរកដៃគូលក់គ្រឿងយន្តកសិកម្ម ។

## II. សភាពការណ៍សេដ្ឋកិច្ចរវាងខេត្តក្វាងស៊ីនិងកម្ពុជា

ចិនជាទីផ្សារដ៏ធំជាងគេនៅក្នុងពិភពលោក ។ ដើម្បីឆ្លើយតបនូវតម្រូវការក្នុងស្រុកខ្ពស់ ចិនបានទៅវិនិយោគនៅប្រទេសជាច្រើននៅក្នុងពិភពលោក ជាពិសេសនៅប្រទេសដែលជាសមាជិកអាស៊ាន ។ ជាក់ស្តែងវិនិយោគ នៅកម្ពុជាចាប់ពីឆ្នាំ២០០៤ រហូតដល់ឆ្នាំ២០១១ ចិនបានដាក់ទុនវិនិយោគដែលមានទឹកប្រាក់រហូតដល់៨.៩១ កោដិដុល្លាអាមេរិក ។ ថ្មីៗនេះ គណប្រតិភូវិនិយោគចិនមួយក្រុមក្នុងខេត្តក្វាងស៊ីដឹកនាំដោយលោក Chen Zhangliang អភិបាលរងខេត្តក្វាងស៊ីបានបំពេញទស្សនកិច្ចសិក្សាស្រាវជ្រាវលទ្ធភាពក្នុងការវិនិយោគដាំដំណាំដំឡូងឈើនិងដាំអំពៅនៅខេត្តមណ្ឌលគិរី ។

នៅខេត្តក្វាងស៊ីមានបើកសិក្ខាសាលាមួយ ស្តីអំពីសក្តានុពលនិងឱកាសវិនិយោគនិងពាណិជ្ជកម្មនៅកម្ពុជា ។ ថ្លែងក្នុងឱកាសនេះលោក Tan Ruixiang អនុប្រធានអង្គប្រជុំសភាពាណិជ្ជកម្មខេត្តក្វាងស៊ីបានថ្លែងថា ចិននិងកម្ពុជាជាមិត្តយូរអង្វែងនិងជាដៃគូសហប្រតិបត្តិការពាណិជ្ជកម្ម ទ្វេភាគី(ចិន-កម្ពុជា)ដែលសំរេចបាន២៥០០លានដុល្លាអាមេរិកក្នុងឆ្នាំ២០១១ ក្នុងនោះការផ្លាស់ប្តូរពាណិជ្ជកម្មរវាងខេត្តក្វាងស៊ី-កម្ពុជាអនុវត្តបានលើសពី១៧លានដុល្លាអាមេរិក ខ្ពស់ជាងឆ្នាំ២០១០ចំនួន៨៧% ។

ផ្អែកតាមមតិរបស់មន្ត្រីជាន់ខ្ពស់របស់សភាពាណិជ្ជកម្មខេត្តក្វាងស៊ីបានថ្លែងថា ក្នុងរយៈពេល៦ខែដើមឆ្នាំ២០១២នេះ ការផ្លាស់ប្តូរពាណិជ្ជកម្មរវាងខេត្តក្វាងស៊ីនិងកម្ពុជាសំរេចបាន១១លានដុល្លាអាមេរិកខ្ពស់ជាងឆ្នាំ២០១១រយៈពេលដូចគ្នាចំនួន២០% ។ មុខទំនិញនៃការផ្លាស់ប្តូរពាណិជ្ជកម្មរវាងខេត្តក្វាងស៊ីនិងកម្ពុជាផ្តោតទៅលើវិស័យកសិកម្ម អង្ករ ឧស្សាហកម្មកែច្នៃនិងអភិវឌ្ឍន៏ធនធានធម្មជាតិ ។

សេចក្តីជូនបានជំរាបជូនខាងលើ សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ប្រចាំខែវិច្ឆិកា ឆ្នាំ២០១២ ដ៏ខ្ពង់ខ្ពស់ដោយអនុគ្រោះ ។

សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ក្រុងណាននីង, ថ្ងៃទី 30 ខែ 11 ឆ្នាំ២០១២

**ទីប្រឹក្សាពាណិជ្ជកម្ម**

**អ៊ុច គឹមយ៉ុន**

ចម្លងជូន

-អគ្គកុងស៊ុលនៅណាននីង

-ឯកសារកាលប្បវត្តិ

Address: No 11, Zhujin Road, China-ASEAN Business District,
Nanning City, Guangxi, China
Tel/Fax : +86-771-5389496
Email : clo_cambodia@yahoo.com